ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប
ASIA EURO UNIVERSITY

លេខ: ០១៧/១១/សអអ/សជណ

## សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងជ្រើសរើសនិស្សិតឱ្យចូលសិក្សាថ្នាក់បណ្ឌិតស្រាវជ្រាវ(Ph.D.)

**យោង:** -ប្រកាសលេខ ២០៨៥ អយក.ប្រក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការបណ្តុះបណ្តាលថ្នាក់បណ្ឌិតជាភាសាជាតិនៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប របស់ក្រសួងអប់រំ យុវជន និងកីឡា
-សេចក្តីសម្រេចលេខ០០៣/០៩ សអអ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៩ ស្តីពី គោលការណ៍បណ្តុះបណ្តាលថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប។

សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប សូមជូនដំណឹងដល់និស្សិត មន្ត្រីរាជការ និង បុគ្គលិកអង្គការនិងក្រុមហ៊ុនឯកជនទាំងពីរភេទ ដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្រដែលមានតម្លៃស្មើ ទាំងក្នុងប្រទេស ឬក្រៅប្រទេស ជ្រាបថា សាកលវិទ្យាល័យនឹងរៀបចំប្រឡងជ្រើសរើសនិស្សិតឱ្យចូលសិក្សាថ្នាក់បណ្ឌិតស្រាវជ្រាវជំនាន់ទី១ ឆ្នាំសិក្សា២០១០-២០១៤ ដូចខាងក្រោម ៖

### ១-លក្ខខណ្ឌជ្រើសរើស

ជ្រើសរើសពីក្នុងចំណោមបេក្ខជនទាំងពីរភេទ៖
១-មានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
២-មានចំណេះដឹងភាសាបរទេស
៣-មានឧបនិស្ស័យក្នុងការស្រាវជ្រាវ

### ២-ការប្រឡងជ្រើសរើស

- កាលបរិច្ឆេទ ៖ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១១
- រយៈពេល ៖ ៣ម៉ោង គឺ ចាប់ពីម៉ោង ១៤:០០នាទី ដល់ ១៧:០០ នាទី
- ទីកន្លែង ៖ សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប បន្ទប់ Ph.D.-A

### ៣-វិញ្ញាសា

- វិញ្ញាសាឯកទេស ៖ រយៈពេល ១:៣០នាទី
- វិញ្ញាសាភាសាបរទេស(ភាសាអង់គ្លេស) ៖ រយៈពេល ១:៣០នាទី

### ៤-សំណើគម្រោងស្រាវជ្រាវបឋម

បេក្ខជនត្រូវរៀបចំគម្រោងស្រាវជ្រាវបឋម(Research Proposal) ចំនួន ០១ច្បាប់ ដែលមានចំនួនពី៥ទៅ៧ទំព័រ (ទំហំក្រដាស៖ A4 , Left 3cm, Right 2.5cm, Top & Bottom 2cm) និងត្រូវប្រើអក្សរខ្មែរយូនីកូដ។
សមាសធាតុគម្រោងបឋម រួមមាន៖

១-ចំណងជើងប្រធានបទបណ្ដោះអាសន្ន

២-ចំណោទបញ្ហា

៣-គោលបំណង

៤-សម្មតិកម្ម

៥-ដែនកំណត់និងវិសាលភាព

៦-កម្មវិធីនិងវិធីសាស្ត្រស្រាវជ្រាវ

៧-ប្លង់ស្រាវជ្រាវបណ្ដោះអាសន្ន(រចនាសម្ព័ន្ធនៃការស្រាវជ្រាវ)

៨-ប្រតិទិនស្រាវជ្រាវ

៩-ការតម្រង់ទិសឯកសារពិគ្រោះ។

*សំណើគម្រោងស្រាវជ្រាវបឋមនេះ បេក្ខជនត្រូវប្រគល់ជូនមកការិយាល័យសិក្សា និងស្រាវជ្រាវ នៅថ្ងៃ ទី២៦ ខែកុម្ភៈ ឆ្នាំ២០១១។*

**៥-សំណុំលិខិតរបស់បេក្ខជន**

បេក្ខជនត្រូវបំពេញសំណុំលិខិតស្នើសុំប្រឡងចុះឈ្មោះចូលសិក្សាស្រាវជ្រាវថ្នាក់បណ្ឌិត ដោយផ្ទាល់ដៃ រួមមាន ៖

| | |
|---|---|
| ១-ឯកសារសុំចុះឈ្មោះប្រឡងនិងចូលសិក្សាស្រាវជ្រាវថ្នាក់បណ្ឌិត(Application Form for Post-Graduate Program) | ចំនួន ០១ច្បាប់ |
| ២-សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬ សញ្ញាបត្រដែលមានតម្លៃស្មើដែល មានការបញ្ជាក់ពីអាជ្ញាធរឬ ស្ថាប័នមានសមត្ថកិច្ច | ចំនួន ០២ច្បាប់ |
| ៣-កិច្ចសន្យាជានារបស់បេក្ខជនបញ្ជាក់ពីការឆ្លងកាត់គ្រប់ភូមិសិក្សាមាន លក្ខណៈជាប្រព័ន្ធនិងប្រក្រតី | ចំនួន ០១ច្បាប់ |
| ៤-សាលកបត្រឯកត្តជនមានបិទរូបថតថ្មី ទំហំ ៤x៦ | ចំនួន ០១ច្បាប់ |
| ៥-រូបថតថ្មី ថតចំពីមុខគ្មានពាក់មួកនិងវ៉ែនតា ទំហំ ៤x៦ | ចំនួន ០៣ច្បាប់ |
| ៦-បង្កាន់ដៃបង់ប្រាក់ | ចំនួន ០១ច្បាប់ |

ចំពោះព័ត៌មានលម្អិតបន្ថែមទៀត បេក្ខជនអាចទាក់ទងផ្ទាល់ជាមួយការិយាល័យសិក្សានិងស្រាវជ្រាវនៃ សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប (ទូរស័ព្ទលេខ : ០១២ ៩៦ ៥៦ ៧៧ ឬ ០៩៧ ៦៧៦ ០១៦៨)។

*<u>បញ្ជាក់៖</u> បេក្ខជនត្រូវបំពេញសំណុំលិខិត តាមការណែនាំរបស់សាកលវិទ្យាល័យឱ្យបានមុនថ្ងៃប្រឡង។*

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០

**សាកលវិទ្យាធិការ**

**ឌួង_លាង**

**ចម្លងជូន៖**

-ក្រសួងអប់រំ យុវជន និងកីឡា

-នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រនៃក្រសួង អយក

-ឯកសារ-កាលប្បវត្តិ